# ប្រព័ន្ធយុត្តិធម៌កម្ពុជា

# ជំពូក១ សាលាជំរះក្តីនៃព្រះរាជាណាចក្រកម្ពុជា

## ផ្នែកទី១ ប្រវត្តិរបស់ប្រព័ន្ធតុលាការនៃព្រះរាជាណាចក្រកម្ពុជា

ប្រព័ន្ធតុលាការបានទទួលរងឥទ្ធិពលពីប្រវត្តិសាស្ត្ររបស់ខ្លួន ។នីតិខ្មែរបុរាណ គឺជានីតិផ្ទាល់មាត់ និងត្រូវបានទ្រទ្រង់ដោយសាសនា ។ក្នុងរបបរាជានិយមសម័យយូរលង់ ព្រះមហាក្សត្រដែលតំណាងអោយអាទិទេព ជាអ្នកកាន់អំនាចគ្រប់ប្រភេទ រួមទាំងអំនាចតុលាការផងដែរ ។ ជារៀងរាល់ថ្ងៃ ព្រះមហាក្សត្របើកសវនាការចូលរួមដោយមន្ត្រីនាម៉ឺន និង ប្រជារាស្ត្របរិយាយបញ្ហាអោយទ្រង់ជួយដោះស្រាយ ទោះបីជារឿងតូចក្តីធំក្តី ។ " យមរាជ " ក្នុងសម័យនោះដែលចាត់ទុកជារដ្ឋមន្ត្រីក្រសួងយុត្តិធម៌ជួយព្រះមហាក្សត្រក្នុងបញ្ហាតុលាការ ។

ចាប់សតវត្សទី១៦មក គេឃើញមានចងក្រងសេចក្តីសំរេចរបស់ព្រះមហាក្សត្រ ដែលបង្កើតជាប្រភពមួយនៃនីតិខ្មែរសម័យនោះ ។ទ្រឹស្តីទេវរាជអនុវត្តរហូតមកដល់ឆ្នាំ១៩២២ ។ ព្រះមហាក្សត្រជាចៅក្រមនៃក្សត្រទាំងអស់ និងជាចៅក្រមនៃមន្ត្រីនានារបស់របស់ទ្រង់ហើយក៏ជាចៅក្រមជាន់ខ្ពស់ក្នុងប្រទេសដែរ ។ ស្ថាប័នតុលាការកម្ពុជាមិនត្រូវបានកែប្រែទាំងស្រុងដោយសន្ធិសញ្ញា ១១ សីហា ១៨៦៣ ដែលបង្កើតអាណាព្យាបាលមកលើខ្មែរឡើយ ព្រោះមាត្រានៃសន្ធិសញ្ញាកំនត់អាណាព្យាបាលបែបសេរីដែលបារាំងដាក់លើខ្មែរ ។ បារាំងធា នាអោយប្រជារាស្ត្រខ្មែរនូវយុត្តាធិការដែលខ្លួនធ្លាប់មាន ។ ទន្ទឹមនឹងនេះជនជាតិបារាំងរឺជនបរទេសដែលរស់ នៅក្នុងប្រទេសខ្មែរត្រូវគោរពយុត្តាធិការបារាំង ។ក្រោយមកវត្តមានរបស់បារាំងកាន់តែខ្លាំងឡើងៗ លើប្រព័ន្ធតុលាការខ្មែរ ។ តាមសន្ធិសញ្ញា១៨៦៣ ព្រះមហាក្សត្រកម្ពុជាយល់ព្រមអោយមានកំណែទំរង់តុលាការគ្រប់ប្រភេទដែលរដ្ឋាភិបាលនៃសាធារណៈរដ្ឋយល់ថាមានរបយោជន៏ទៅថ្ងៃអនាគត ។ឥទ្ធិពលរបស់បារាំងស្តែងតាមរយៈការអនុវត្តន៏ច្បាប់សរសេរដែលជាប្រព័ន្ធ Civil Law នៅកម្ពុជាដែលនីតិចាប់ចងក្រងជាក្រម នៅថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ១៩២0 សម្តេចព្រះស៊ីសុវត្ថិ បានប្រកាសអោយប្រើប្រាស់ប្រព័ន្ធរដ្ឋប្បវេណីថ្មី ។ក្រមនេះជាប្រភពកំណើតដល់ក្រមនីតិរដ្ឋប្បវេណីប្រកាសអោយប្រើនៅថ្ងៃទី ១៨ ខែធ្នូ ឆ្នាំ១៩៣៨ ។ ពេលនោះហើយដែលតុលាការខ្មែរមានលក្ខណៈដូចគ្នាទាំងស្រុងទៅនឹងទៅនឹងស្ថាប័នតុលាការបារាំង ។

- ៩ វិច្ឆិកា ១៩៥៣ ជាថ្ងៃប្រកាសឯករាជ្យ ប៉ុន្តែនៅតែទទួលឥទ្ធិពលយ៉ាងពេញទំហឹងពីច្បាប់បារាំងដដែលរហូតដល់សម័យសាធារណៈរដ្ឋខ្មែរ ។
- របបខ្មែរក្រហម១៩៧៥ - ១៩៧៩ ប្រព័ន្ធយុត្តិធម៌ខ្មែរត្រូវបាត់ទាំងស្រុង ដោយបញ្ញាវ័ន្ត អ្នកច្បាប់ត្រូវសំលាប់ចោលស្ទើរតែទាំងស្រុង ។

- ក្រោយឆ្នាំ១៩៧៩ កម្ពុជាព្យាយាមស្ថាបនាឡើងវិញប្រព័ន្ធតុលាការផ្អែកលើប្រពៃណីខ្មែរ និងគោលការណ៍កំនត់ដោយស្ថាប័នអន្តរជាតិ ។ឆន្ទៈក្នុងការស្ថាបនាវិស័យតុលាការឡើងវិញ ត្រូវបានគូសបញ្ជាក់នៅក្នុងកិច្ចព្រមព្រៀងក្រុងប៉ារីស ២៣ តុលា ១៩៩៣ និងច្បាប់ព្រហ្មទណ្ឌចុះថ្ងៃទី១០ កញ្ញា ១៩៩២ ដែលតាមនោះក្រុមប្រឹក្សាជាតិជាន់ខ្ពស់ បានអនុវត្តលើបញ្ញត្តិស្តីពីប្រព័ន្ធតុលាការច្បាប់ព្រហ្មទណ្ឌ និងនីតិវិធីព្រហ្មទណ្ឌសំរាប់អនុវត្តនៅកម្ពុជាក្នុងសម័យអន្តរកាលដែលត្រូវរៀបចំដោយ UNTAC ។

សមត្ថកិច្ចរបស់តុលាការ គឺជាស្ថាប័នរដ្ឋដែលច្បាប់បានប្រគល់សិទ្ធិអំណាចអោយទទួលដោះស្រាយពាក្យបណ្តឹង ។តាមសម័យទំនើបបច្ចុប្បន្ននេះ ស្ថាប័នតុលាការ ជាស្ថាប័នឯករាជ្យ ។

ស្ថាប័នតុលាការ គេអាចហៅម្យ៉ាងទៀតថាគណៈយុត្តាធិការ ដែលមានន័យដូចខាងក្រោម :

- ជាការសំដៅអំណាចសំរេច កាត់សេចក្តីរាល់បណ្តឹង
- ជាស្ថាប័នមានអំណាចសំដៅលើសាលាជំរះក្តីគ្រប់ជាន់ ។

ស្របតាមការសិក្សានិតិសាធារណៈ និង នីតិឯកជនដែលធ្វើអោយយើងមានចំងល់ទៅលើយុត្តិធម៌សាធារណៈ Justice Publique និងពាក្យថា យុត្តិធម៌ឯកជន Justice Prive ។

**យុត្តិធម៌សាធារណៈ** គឺជាមុខងារដ៏ចំបងរបស់រដ្ឋដែលធ្វើអោយមានរបៀបរៀបរយល្អក្នុងសង្គម ដូច្នេះប្រសិនបើប្រជាពលរដ្ឋមានវិវាទរឿងក្តីណាមួយ ដាច់ខាតត្រូវពឹងរដ្ឋដែលមានតុលាការសំរេចសេចក្តី ។

**យុត្តិធម៌ឯកជន** បានសេចក្តីថាប្រសិនបើប្រជាបលរដ្ឋមានជំលោះ គឺគាត់ខិតខំសំរបសំរួលវិវាទដោយខ្លួនឯងដោយពុំចាំបាច់ប្តឹងទៅតុលាការទេ ។ រាល់ការសំរេចដោយយុត្តិធម៌ឯកជននេះ វានាំអោយចំណេញពេលវេលា និងមិនមានបញ្ហាវែងឆ្ងាយ ។ ករណីនេះហើយ ដែលធ្វើអោយសង្គមជាតិនីមួយៗតែងតែជួបប្រទះនូវករណី២យ៉ាង គឺការសំរុះសំរួលក្រៅផ្លូវតុលាការ និងអំនាចតុលាការដែលមានអំនាចសំរេចសេចក្តីតាមរយៈសាលក្រម រឺសាលដីកា សន្មតថាអ្នកខុស និងអ្នកត្រូវ ។

ការជំនុំជំរះ គឺជាមុខងារមួយក្នុងចំនោមមុខងារសំខាន់របស់រដ្ឋ ។អត្ថិភាពសាលាជំរះក្តីគឺចេញមកពីគោលការណ៍នៃការបែងចែកអំនាច ជាពិសេសរវាងអំនាចនីតិប្រតិបត្តិ និងអំនាចតុលាការ ។

យុត្តាធិការបំពេញមុខងារ២យ៉ាងគឺ :

- ជាការជំរះក្តីឯកជន និងឯកជនដែលគេហៅថា : យុត្តាធិការរដ្ឋប្បវេណី រឺសភារដ្ឋប្បវេណី
- ការដាក់ទណ្ឌកម្មលើជនដែលប្រព្រឹត្តខុសច្បាប់ គេហៅថា : យុត្តាធិការព្រហ្មទណ្ឌ រឺសភាព្រហ្មទណ្ឌ ។

ដូច្នេះសាលាជំរះក្តីជាច្រើនមានយុត្តាធិការរដ្ឋប្បវេណីផង និងយុត្តាធិការព្រហ្មទណ្ឌផង ។

## ផ្នែកទី២ ប្រព័ន្ធតុលាការកម្ពុជា

យោងតាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាដែលបានអនុម័តនៅថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ ១៩៩៣ បានចែងថា " អំនាចតុលាការជាអំនាចឯករាជ្យ " ។ អំនាចតុលាការគបដណ្តប់ទៅលើរឿងក្តីទាំងអស់ រួមទាំងរឿងក្តីរដ្ឋបាលផង ។អំនាចត្រូវប្រគល់អោយតុលាការកំពូល និងសាលាក្តីគ្រប់ជាន់ថ្នាក់ ។ការជំរះក្តីត្រូវធ្វើឡើងក្នុងនាមប្រជារាស្ត្រខ្មែរតាមនីតិវិធីជាធរមាន ។ មានតែចៅក្រមទេដែលមានសិទ្ធិជំរះក្តី ។ ចៅក្រមត្រូវបំពេញភារកិច្ចនេះដោយគោរពច្បាប់យ៉ាងម៉ឺងម៉ាត់ និងអស់ពីដួងចិត្ត និងសតិសម្បជញ្ញៈរបស់ខ្លួន ។

សាលាជំរះក្តីនៅព្រះរាជាណាចក្រកម្ពុជាត្រូវបែងចែកជា២ជាន់ថ្នាក់ គឺតុលាការជាន់ទាប និងតុលាការជាន់ខ្ពស់ ។

- តុលាការជាន់ទាបមានតុលាការខេត្តក្រុង និងយោធាដែលគេហៅម្យ៉ាងទៀតថាជា សាលាដំបូង ។
- តុលាការជាន់ខ្ពស់មានសាលាឧទ្ធរណ៍ និងតុលាការកំពូល ។

### I.តុលាការជាន់ទាប

### ក.តុលាការខេត្តក្រុង

តុលាការខេត្តក្រុងដែលតាំងក្នុងខេត្តក្រុងណាមានសមត្ថកិច្ចដោះស្រាយតែរឿងក្តីទាំងឡាយណាដែលកើតឡើងក្នុងរង្វង់ដែនដីនៃខេត្តក្រុងដែលតុលាការនោះតាំងនៅតែប៉ុណ្ណោះ ។

យោងតាមច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពសាលាជំរះក្តីនៃរដ្ឋកម្ពុជាអនុម័តនៅថ្ងៃទី២២ ខែមករា ឆ្នាំ១៩៩៣បានចែងថា " តុលាការខេត្តក្រុងមានសមត្ថកិច្ចជំនុំជំរះបើកផ្លូវឧទ្ធរណ៍នូវរឿងក្តីព្រហ្មទណ្ឌ រឿងក្តីរដ្ឋប្បវេណី រឿងពាណិជ្ជកម្ម រឿងវិវាទរដ្ឋបាល និងវិវាទការងារ " ។ នៅងមតុលាការខេត្តក្រុងមានអយ្យការ ។

### សមាសភាពជំនុំជំរះក្តី

តុលាការខេត្តក្រុងមានសមាសភាពជំនុំជំរះក្តីដូចតទៅ :

- ចៅក្រម ១រូប ជាប្រធាន
- ព្រះរាជអាជ្ញា ១រូប
- ក្រឡាបញ្ជី ១រូប

- មេធាវី ១រូប រឺជាច្រើនរូបតាមលទ្ធភាពរបស់កូនក្តី តែមេធាវីមិនចាត់ចូលក្នុងសមាសភាពតុលាការ តុលាការទេ ។

នៅតុលាការខេត្តក្រុងមានប្រធានតុលាការ អនុប្រធានតុលាការ និងចៅក្រមដែលត្រូវបានចាត់តាំងអោយបំពេញមុខងារ ផ្លាស់ប្តូរ តំឡើងឋានន្តរស័ក្តិ រឺដកហូតងារដោយព្រះរាជក្រឹត្យតាមសំណើរបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ។

**អានុភាពសាលក្រម**

សេចក្តីសំរេចរបស់តុលាការខេត្តក្រុង គេហៅថាសាលក្រម ។

សាលក្រមមាន២ប្រភេទ គឺ :

- **សាលក្រមជំរះសេចក្តីចំពោះមុខ** បើកបណ្តឹងឧទ្ធរណ៍ក្នុងរយៈពេល៣០ថ្ងៃ គិតចាប់ពីថ្ងៃកាត់សេចក្តី ។

- **សាលក្រមចំពោះមុខ** បើកអោយប្តឹងជំទាស់ ក្នុងរយៈពេល១៥ថ្ងៃ ចាប់គិតពីថ្ងៃជូនដំណឹង ។បើផុតប្តឹងជំទាស់ អាចប្តឹងឧទ្ធរណ៍បានក្នុងរយៈពេល៣០ថ្ងៃ គិតពីថ្ងៃផុតប្តឹងជំទាស់ ។

បណ្តឹងឧទ្ធរណ៍មានអានុភាពផ្អាកជាបណ្តោះអាសន្ននូវការអនុវត្តសាលក្រម ។ បណ្តឹងឧទ្ធរណ៍ដែលទាក់ទងដល់សេចក្តីសំរេចរបស់តុលាការ ចៅក្រម រឺ ព្រះរាជអាជ្ញាពុំមានអានុភាពផ្អាកសេចក្តីសំរេចនោះលើកលែងតែបណ្តឹងឧទ្ធរណ៍ធ្វើឡើងដោយ ព្រះរាជអាជ្ញាក្នុងរឿងឃុំខ្លួន រឺ ដោះលែងអោយនៅក្រៅឃុំជាបណ្តោះអាសន្ន ។

បណ្តឹងឧទ្ធរណ៍ត្រូវធ្វើឡើងនៅសាលាជំរះក្តីដែលចេញសាលក្រមនោះ ។

បុគ្គលដែលមានសិទ្ធិប្តឹងឧទ្ធរណ៍ រឺប្តឹងជំទាស់មាន ព្រះរាជអាជ្ញា រឺ ជនទាំងឡាយណាដែលមានប្រយោជន៍ពាក់ព័ន្ធក្នុងរឿងក្តីរួមមាន កូណក្តី ដើមបណ្តឹងរដ្ឋប្បវេណី ជនជាប់ចោទ អ្នកទទួលខុសត្រូវខាងរដ្ឋប្បវេណី ជនជាប់ទោស មេធាវី រឺអ្នកការពារក្តី ។ ក្រៅពីរឿងព្រហ្មទណ្ឌ ព្រះរាជអាជ្ញាជាគូក្តីដើមជានិច្ច ក្នុងន័យនេះព្រះរាជអាជ្ញាធ្វើបណ្តឹងអាជ្ញាដោយចោទប្រកាន់ជនជាប់ចោទ និងសុំអនុវត្តច្បាប់លើជននោះ ។

**ខ.តុលាការយោធា**

តុលាការយោធា ក៏ដូចជាតុលាការខេត្តក្រុងដែរ តុលាការមានតែមួយទេ តាំងរាជធានីភ្នំពេញមានសមត្ថកិច្ចលាតសន្ធឹងលើផ្ទៃប្រទេសទាំងមូល ហើយត្រូវដោះស្រាយតែចំពោះរឿងក្តីទាំងឡាយដែលបង្កឡើងដោយយោធិន ប៉ះពាល់កងទ័ព រឺទ្រព្យសម្បត្តិ រឺ វិន័យរបស់កងទ័ព ។

តុលាការយោធាទទួលជំនុំជំរះតែបទល្មើសយោធាទេ ។បទល្មើសយោធា គឺជាបទល្មើសដែលទាក់ទិនដល់យោធិន ទាំងយោធិនជាប់កិច្ចសន្យា ទាំងយោធិនកំណែន ហើយដែលមានពាក់ព័ន្ធនឹងវិន័យយោធា រឺការខូចខាតទ្រព្យសម្បត្តិយោធា ។ រាល់បទឧក្រិដ្ឋ រឺបទល្មើសនឹងច្បាប់សាមញ្ញដែលប្រព្រឹត្តដោយយោធិន គឺត្រូវជំរះនៅតុលាការខេត្តក្រុង ។

តុលាការយោធាមានសមត្ថកិច្ចជំនុំជំរះ បើកផ្លូវឧទ្ធរណ៏នូវបទល្មើសយោធា ។ នីតិវិធីរបស់តុលាការយោធាដូចគ្នានឹងនីតិវិធីតុលាការខេត្តក្រុងដែរ ។

សេចក្តីសំរេចរបស់តុលាការយោធា គេហៅថាសាលក្រម ។

**សមាសភាពជំនុំជំរះ :**

- ចៅក្រម ១រូបជាប្រធាន មានឋានន្តរស័ក្តិជាយោធា
- ព្រះរាជអាជ្ញា ១រូប មានឋានន្តរស័ក្តិជាយោធា
- ក្រឡាបញ្ជី ១រូប មានឋានន្តរស័ក្តិជាយោធា
- មេធាវី ១រូប រឺច្រើនរូបតាមលទ្ធភាពរបស់កូនក្តី តែមេធាវីពុំចាត់ចូលក្នុងសមាសភាពតុលាការទេ ។

## II.តុលាការជាន់ខ្ពស់

### ក.សាលាឧទ្ធរណ៏

សាលាឧទ្ធរណ៏ជមនុំជំរះទាំងអស់ ទាំងអង្គហេតុ និង អង្គច្បាប់ មានសមត្ថកិច្ចជំរះលើបណ្តឹងឧទ្ធរណ៏អំពីសាលក្រមរបស់តុលាការខេត្តក្រុង និងយោធា ដោយបើកផ្លូវអោយប្តឹងសារទុក្ខ ។

សាលាឧទ្ធរណ៏មានតែមួយ តាំងនៅរាជធានីភ្នំពេញដោយមានសមត្ថកិច្ចលាតសន្ធឹងលើដែនដីនៃព្រះរាជាណាចក្រកម្ពុជាទាំងមូល ។ សាលាឧទ្ធរណ៏ទទួលដោះស្រាយរាល់បណ្តឹងឧទ្ធរណ៏របស់គូក្តីដែលប្តឹងមិនសុខចិត្តនឹងសាលក្រមរបស់តុលាការខេត្តក្រុង រឺយោធា ។

**សមាសភាពជំនុំជំរះ**

- ចៅក្រម ៣រូប ១រូបជាប្រធាន
- អគ្គព្រះរាជអាជ្ញា រឺអគ្គព្រះរាជអាជ្ញារង រឺព្រះរាជអាជ្ញា
- ក្រឡាបញ្ជី ១រូប
- មេធាវី ១រូប រឺ ច្រើនរូបតាមលទ្ធភាពរបស់កូនក្តី តែមេធាវីពុំចាត់ចូលក្នុងសមាសភាពតុលាការទេ ។

សេចក្តីសំរេចរបស់សាលាឧទ្ធរណ៏ គេហៅថាសាលដីកា ( អានុភាពសាលដីកា) ។

សាលដីកាសាលាឧទ្ធរណ៍សំរេចសេចក្តីចំពោះមុខអាចប្តឹងសារទុក្ខក្នុងរយៈពេល២ខែ គិតពីថ្ងៃកាត់សេចក្តី ។សាលដីកាកំបាំងមុខអាចប្តឹងជំទាស់ក្នុងរយៈពេល១៥ថ្ងៃ គិតចាប់ពីថ្ងៃទទួលដំណឹង ។

បើផុតរយៈពេលប្តឹងជំទាស់អាចប្តឹងសារទុក្ខបានក្នុងរយៈពេល២ខែគិតពីថ្ងៃផុតកំណត់ប្តឹងជំទាស់ ។ ប្តឹងសារទុក្ខមានអានុភាពផ្អាកជាបណ្តោះអាសន្ននូវការអនុវត្តសាលដីការបស់សាលាឧទ្ធរណ៍ ប៉ុន្តែបណ្តឹងសារទុក្ខដែលទាក់ទងនឹងការឃុំខ្លួនបណ្តោះអាសន្ន ។ ការដាក់អោយនៅក្រៅឃុំជាបណ្តោះអាសន្ន ការតំកល់រឿងមិនចាត់ការ និងការលើកសេចក្តីចោទប្រកាន់ កឺមិនមានអានុភាពផ្អាកការអនុវត្តសាលដីកាសាលាឧទ្ធរណ៍ឡើយ ។បណ្តឹងសារទុក្ខត្រូវធ្វើនៅសាលាឧទ្ធរណ៍ដែលចេញសាលដីកានេះ ។

បុគ្គលដែលមានសិទ្ធិប្តឹងសារទុក្ខ និងប្តឹងជំទាស់នឹងសាលដីការបស់សាលាឧទ្ធរណ៍ គឺអគ្គព្រះរាជអាជញ្ញាសាលាឧទ្ធរណ៍ រឺ ជនដែលមានប្រយោជន៍ក្នុងរឿងទាំងឡាយរួមមាន : គូក្តីដើមបណ្តឹងរដ្ឋប្បវេណី អ្នកទទួលខុសត្រូវខាងរដ្ឋប្បវេណី ជនជាប់ចោទ មេធាវីអ្នកការពារក្តី ។

**នីតិវិធីក្នុងសវនាការសាលាឧទ្ធរណ៍**

ពេលធ្វើសវនាការដែលកំនត់ដោយសាលាឧទ្ធរណ៍ មុនពេលចាប់ផ្តើមជំនុំជំរះ ក្រឡាបញ្ជីអាននូវអត្ថបទបញ្ជាផ្ទៃក្នុងសំរាប់ការជំនុំជំរះជូនអង្គសវនាការ ។ពេលចៅក្រមចូលមកដល់ ជនគ្រប់គ្រប់រូបដែលចូលដែលចូលរួមក្នុងសវនាការត្រូវក្រោកឈរ រួចអង្គុយចុះវិញ ក្រោយពីទទួលប្រសាសន៍បង្គាប់របស់ប្រធានចៅក្រម ។ បន្ទាប់មកប្រធានចៅក្រមថ្លែងបើកសវការគំរូតាមលំដាប់លំដោយនៃការបើកសវនាការរបស់សាលាឧទ្ធរណ៍ ។

**ខ.តុលាការកំពូល**

**១.រចនាសម្ព័ន្ធ**

តុលាការកំពូលត្រូវបែងចែកជា២ផ្នែក គឺតុលាការ មហាអយ្យការអមតុលាការកំពូល ។

- តុលាការ :ក្នុងផ្នែកនេះរួមមាន :

  - ប្រធានតុលាការកំពូលមួយរូប តែងតាំងដោយក្រឹត្យតាមសំណើររបស់រដ្ឋសភាដែលមានឋានៈស្មើឧបនាយករដ្ឋមន្ត្រី ។ប្រធានមាននាទីត្រួតពិនិត្យរាល់កិច្ចការក្នុងតុលាការ ។
  - អនុប្រធានតុលាការកំពូលមួយរូប តែងតាំងដោយក្រឹត្យតាមសំណើរនាយករដ្ឋមន្ត្រីដែលមានឋានៈស្មើទេសរដ្ឋមន្ត្រី ហើយទទួលបន្ទុកលើរាល់រឿងក្តីបណ្តឹងក្នុងតុលាការ និងផ្នែកផ្សេងនៃតុលាការ ។

˙ សភាព្រហ្មទណ្ឌដែលមានសមាសភាពជាចៅក្រម៤រូប និង ក្រឡាបញ្ជីជាច្រើនរូបទៀត មានភារកិច្ចទទួលបន្ទុកលើសំណុំរឿងទាំងឡាយដែលពាក់ព័ន្ធនឹងរឿងព្រហ្មទណ្ឌ។

˙ សភារដ្ឋប្បវេណីមានសមាសភាពជាចៅក្រម៥រូប និងក្រឡាបញ្ជីច្រើនរូបទៀតមានភារកិច្ចទទួលបន្ទុកលើសំណុំរឿងទាំងឡាយដែលពាក់ព័ន្ធនឹងរឿងរដ្ឋប្បវេណី។

✦ បញ្ជាក់ : ចៅក្រមក្នុងសភាមួយអាចជំនុំជំរះរឿងក្តីនៅសភាមួយទៀតបានដែរ ក្នុងករណីចាំបាច់។

- នាយកដ្ឋានសរុប និងត្រួតពិនិត្យមានចៅក្រម៣រូប និងច្រើនរូបទៀតមានភារកិច្ច :

˙ តម្កល់ទុកសំនុំរឿង

˙ បោះពុម្ពសាលដីការបស់តុលាការកំពូល

˙ ផ្ញើររបាយការណ៍បូកសរុប និងត្រួតពិនិត្យលិខិតបទដ្ឋាននានារបស់តុលាការកំពូល

˙ ទទួល និងត្រួតពិនិត្យសំនុំរឿងដេលបញ្ជូនពីសាលាឧទ្ធរណ៍

- ផ្នែកមន្ទីរតុលាការកំពូលដែលចែកបន្តជាការិយាល័យចំនួន៤ :

˙ ការិយាល័យគណនេយ្យ និងសំភារៈ

˙ ការិយាល័យរដ្ឋបាល

˙ ការិយាល័យបុគ្គលិក

˙ ការិយាល័យប្រដាប់ក្តី ( ការិយាល័យក្រឡាបញ្ជីនាយក )

៤ មហាអយ្យការអមតុលាការកំពូល :មានសមាសភាពដូចតទៅ :

- អគ្គព្រះរាជអាជ្ញា ១រូបតែងតាំងដោយក្រឹត្យតាមការយល់ព្រមពីរដ្ឋសភា ហើយមានឋានៈស្មើអនុប្រធានក្រុមប្រឹក្សារដ្ឋមន្រ្តី។

- ព្រះរាជអាជ្ញារង ១រូប តែងតាំងដោយក្រឹត្យតាមសំណើររបស់ក្រសួងយុត្តិធម៌មានឋានៈស្មើរដ្ឋមន្រ្តី។

- ព្រះរាជអាជ្ញាច្រើនរូបស្ថិតក្រោមបង្គាប់របស់អគ្គព្រះរាជអាជ្ញា

តួនាទី និងភារកិច្ចរបស់មហាអយ្យការអមតុលាការកំពូល :

˙ ត្រួតពិនិត្យនីត្យានុកូលភាពនៃការស៊ើបអង្កេតតាំងពីដើមដល់ចប់ និង មានសិទ្ធិត្រួតពិនិត្យលិខិតបទដ្ឋានដែលពាក់ព័ន្ធមានដូចជា លិខិតចោទប្រកាន់ ភស្តុតាង បង្វិលភស្តុតាង ស៊ើបដោយផ្ទាល់ សំរេចចោទប្រកាន់ រឺមិនចោទប្រកាន់...

៉ ប្រើសិទ្ធិជាអយ្យការក្នុងពេលជំនុំជំរះដោយអានលិខិតចោទប្រកាន់ និងធ្វើរសេចក្តីសន្និដ្ឋានក្រោយការដេញដោលសួរ តាំងខ្លួនជាគូក្តី គុក្តីក្នុងបណ្តឹងអាជ្ញា...

៉ ត្រួតពិនិត្យការអនុវត្តន៏សាលក្រម ( ត្រួតពិនិត្យការអនុវត្តន៏ទណ្ឌកម្មចំពោះទណ្ឌិត ដោះលែងជនជាប់ចោទដែលតុលាការសំរេចអោយរួចទោស...។

**២.សមត្ថកិច្ច និងមុខងារតុលាការកំពូល**

តុលាការកំពូល គឺជាសាលាជំរះក្តីដែលមានឋានានុក្រមខ្ពស់បំផុតនៃព្រះរាជាណាចក្រកម្ពុជា វាមានសមត្ថកិច្ចគ្របដណ្តប់លើសាលាជំរះក្តីនៅទូទាំងប្រទេសដែលរួមមានតុលាការខេត្តក្រុង តុលាការយោធា និងសាលាឧទ្ធរណ៏។

តុលាការកំពូលមានសិទ្ធិត្រួតពិនិត្យលើគ្រប់សាលដីការរបស់សាលាឧទ្ធរណ៏ដែលមានកំហុស។ ការត្រួតពិនិត្យអាចប្រព្រឹត្តទៅបាន ក្នុងករណីមានបណ្តឹងសារទុក្ខពីភាគីណាមួយ នៅក្នុងរឿងក្តីដែលមិនសុខចិត្តនឹងសាលដីកាសាលាឧទ្ធរណ៏ ។តុលាការកំពូលត្រូវសំសេចលក្ខណៈត្រឹមត្រូវ រឺមិនត្រឹមត្រូវរបស់សាលដីកានោះ ។ជាធម្មតាតុលាការកំពូលជំនុំជំរះតែលើអង្គច្បាប់តែប៉ុណ្ណោះ លើកលែងតែក្នុងករណីពិសេស។

**អំពីបណ្តឹង ៈ**

- **បណ្តឹងសារទុក្ខ** ៈ ជាពាក្យជំទាស់ប្រឆាំងនឹងសេចក្តីសំរេចមួយដែលចេញជាលើកចុងក្រោយដោយចៅក្រមអង្គហេតុ ហើយដែលធ្វើចំពោះមុខតុលាការកំពូល ។ដូចនេះបណ្តឹងសារទុក្ខជាអំនាចដែលច្បាប់បើកសិទ្ធិអោយភាគីណាមួយដែលស្វែងរកការស្តារសិទ្ធិរបស់ខ្លួនឡើងវិញនៅចំពោះមុខតុលាការកំពូល។ បណ្តឹងនេះមានអានុភាពពន្យាការអនុវត្តន៏សាលក្រមរបស់សាលាឧទ្ធរណ៏ រហូតដល់សាលដីកាតុលាការកំពូលត្រូវបានប្រកាស។ បណ្តឹងសារទុក្ខអាចធ្វើបាននៅក្នុងអំឡុងពេល២ខែ បន្ទាប់ពិសាលដីកាសាលាឧទ្ធរណ៏ប្រកាស ។បន្ទាប់ពីទទួលបណ្តឹងហើយ តុលាការកំពូលពិនិត្យទៅលើសាលដីកាសាលាឧទ្ធរណ៏ ។ បើឃើញមានកំហុសផ្នែកទំរង់ រឺ គតិច្បាប់ណាមួយតុលាការកំពូលត្រូវបដិសេធសេចក្តីសំរេចនោះចោលជាអាសារបង់ ដោយបង្វិលសំនុំរឿងអោយ

សាលាឧទ្ធរណ៏ជំនុំជំរះសាជាថ្មី ។ប៉ុន្តែបើមានបណ្តឹងសារទុក្ខជាលើកទី២ ដោយមូលហេតុចៅក្រមសាលាឧទ្ធរណ៏ពុំបានសំរេចតាមសេចក្តីណែនាំរបស់តុលាការកំពូល ពេលនោះនាំអោយតុលាការកំពូលជំនុំជំរះទាំងអង្គច្បាប់ និងអង្គហេតុ ។ ការជំនុំជំរះនេះជាលើកទី១ និង ជាលើកចុងក្រោយបង្អស់នូវរឿងក្តីទាំងឡាយណាដែលធ្ងន់ធ្ងរ និងស្មុគស្មាញ។

✦ បញ្ជាក់ ៈ

- សេចក្តីសំរេចរបស់តុលាការកំពូល ត្រូវទុកជានីតិក្រមសំរាប់អោយតុលាការថ្នាក់ក្រោមគោរពតាមគំរូទៅអនាគត ។

- បើមានបណ្តឹងសើរើរដ្ឋប្បវេណីវិញ តុលាការកំពូលមិនអនុញ្ញាតអោយមានទេ ព្រោះសេចក្តីសំរេចរបស់តុលាការកំពូលជាសេចក្តីសំរេចអធិបតេយ្យ ពុំមានច្បាប់ណាមួយអាចអោយបណ្តឹងសើរើបានឡើយ លើកលែងតែក្នុងរឿងព្រហ្មទណ្ឌដែលមានច្បាប់ចែងអោយមានបណ្តឹងសើរើបាន ។

- **បណ្តឹងសើរើ** : បណ្តឹងនេះ គឺជាមធ្យោបាយចុងក្រោយរបស់ទណ្ឌិតក្នុងរឿងព្រហ្មទណ្ឌ ដើម្បីកំណត់សុច្ចរិតភាពរបស់គេឡើងវិញ ។

- **បណ្តឹងសើរើអាចធ្វើបាន :**

- កាលណាក្រោយពីផ្តន្ទាទោសធ្វើមនុស្សឃាត ស្រាប់តែមានភស្តុតាងបញ្ជាក់អោយឃើញច្បាស់លាស់ថាជនរងគ្រោះអំពីមនុស្សឃាតនៅមានជីវិត ។

- កាលណាមានសាលដីកា២ជាន់គ្នា មានសាលដីកា២ដោយឡែកពីគ្នា ដែលអនុវត្តទោសដោយសារអង្គហេតុដូចគ្នា

- មានភស្តុតាងថ្មីដែលបញ្ជាក់ពិសុច្ចរិតភាបរបស់ទណ្ឌិត ។

- កាលណាតុលាការរកឃើញថា សាក្សីផ្តល់ចំលើយក្លែងក្លាយនោះ សុច្ចរិតភាពរបស់ទណ្ឌិតប្រាកដជាមានពុំខាន ។

- អ្នកដែលមានសិទ្ធិធ្វើបណ្តឹងសើរើគឺ :

- រដ្ឋមន្រ្តីក្រសួងយុត្តិធម
- ទណ្ឌិត រឺតំណាងពេញច្បាប់របស់គេ
- សហព័ន្ធឪពុកម្តាយ កូន និងសាច់ញាតិរបស់ទណ្ឌិត ។

**សមាសភាពជំនុំជំរះនៅសាលាឧទ្ធរណ៍**

- **បណ្តឹងសារទុក្ខលើកទី១ :**

- ចៅក្រមចំនួន ៥រូប " ១រូបជាប្រធាន ៤រូបជាចៅក្រមប្រឹក្សា "
- អគ្គព្រះរាជអាជ្ញា រឺអគ្គព្រះរាជអាជ្ញារង រឺព្រះរាជអាជ្ញា ១រូប
- ក្រឡាបញ្ជី ១រូប

- មេធាវី ១រូប រឺ ច្រើនរូបតាមលទ្ធភាពរបស់កូនក្តី តែមេធាវីពុំចាត់ចូលក្នុងសមាសភាពតុលាការទេ។

- **បណ្តឹងសារទុក្ខលើកទី២ :**

ជាករណីជំនុំជំរះរួមក្រុម សមាសភាពជំនុំជំរះរួមមាន :

- ចៅក្រមចំនួន ៥រូប " ១រូបជាប្រធាន ៤រូបជាចៅក្រមប្រឹក្សា"
- អគ្គព្រះរាជអាជ្ញា រឺអគ្គព្រះរាជអាជ្ញារង រឺព្រះរាជអាជ្ញា ១រូប
- ក្រឡាបញ្ជី ១រូប
- មេធាវី ១រូប រឺ ច្រើនរូបតាមលទ្ធភាពរបស់កូនក្តី តែមេធាវីពុំចាត់ចូលក្នុងសមាសភាពតុលាការទេ។

នីតិវិធីនៃការជំនុំជំរះ គឺស្រដៀងគ្នានឹងតុលាការថ្នាក់ក្រោមដែរ ។

**សមាសភាព** :ក្រុមប្រឹក្សាជំនុំជំរះមានចៅក្រម៥រូប ក្នុងនោះប្រធានតុលាការកំពូល គឺជាប្រធានក្រុមប្រឹក្សាជំនុំជំរះ ។ក្នុងសវនាការនេះក៏ត្រូវបំពេញតំណាងរបស់មហាអយ្យការ និងក្រឡាបញ្ជីជំនុំជំរះដែរ ។

**សវនាការ** :សវនាការត្រូវធ្វើជាសាធារណៈ សាលដីកាត្រូវប្រកាសជាសាធារណៈដែរ ។

- ប្រធានប្រកាសបើកសវនាការជំនុំជំរះ ភាគីបណ្តឹងទាំងសងខាងបង្ហាញអត្តសញ្ញាណ
- តំណាងអគ្គព្រះរាជអាជ្ញាធ្វើសេចក្តីសន្និដ្ឋានខាងផ្នែកច្បាប់អំពីបណ្តឹងសារទុក្ខនោះ
- ដើមបណ្តឹងសារទុក្ខឡើងបង្ហាញសំអាងរបស់ខ្លួនថែមលើសារណា
- ចុងចំលើយសារទុក្ខបង្ហាញសំអាងតទល់
- មេធាវីទាំងសងខាងឡើងថ្លែងសំអាងផ្លូវច្បាប់
- ក្រុមប្រឹក្សាជំនុំជំរះចូលក្នុងបន្ទប់ពិភាក្សា ។

**ដំណើរការពិភាក្សា** : ចៅក្រមនីមួយៗផ្តល់សេចក្តីសន្និដ្ឋានផ្ទាល់មាត់ ឯចៅក្រមរបាយការណ៏ជាអ្នកកត់សំគាល់ ។

**ប្រកាសសាលដីកា** ។

## ជំពូកទី២ សមាសភាពមុខងារ និងតួនាទីដែលពាក់ព័ន្ធតុលាការ

### ផ្នែកទី១ ស្ថាប័នអយ្យការ

អយ្យការ គឺជាចៅក្រមដែលទទួលបន្ទុកខាងការត្រួតពិនិត្យការអនុវត្តន៏ច្បាប់នៅចំពោះមុខសាលាជំរះក្តី ។ក្រុមអយ្យការនៅអមសាលាចំរះក្តីខេត្តក្រុង ហៅថា" អយ្យការ " នៅអមសាលាឧទ្ធរណ៏ និងតុលាការកំពូលហៅថា" មហាអយ្យការ "។ព្រះរាជអាជ្ញា ជាតំណាងអោយក្រុមអយ្យការដែលមានក្របខណ្ឌចៅក្រម ហើយត្រូវបានគេហៅថា" ចៅក្រមឈរ "ព្រោះនៅក្នុងសវនាការ ព្រះរាជអាជ្ញាជាអ្នកចោទប្រកាន់ទៅតុលាការ ។

### ក.អយ្យការអមតុលាការខេត្តក្រុង

នៅអមតុលាការខេត្តក្រុង មានការិយាល័យអយ្យការមួយនៅអមតុលាការ ដែលជាស្ថាប័នមានសិទ្ធិជាម្ចាស់បណ្តឹងអាជ្ញា រឺធ្វើបណ្តឹងអាជ្ញា ។ស្ថាប័នអយ្យការមានសមត្ថកិច្ចដែនដីដូចតុលាការដែរ ហើយមានឥទ្ធិពលគ្របលើដីរបស់ខ្លួន មិនអាចឆ្លងដែនសមត្ថកិច្ចបានទេ ។

មុខងាររបស់ស្ថាប័នអយ្យការ :

- ដាក់រឿងអោយតុលាការជំនុំជំរះផ្ទាល់
- ដាក់រឿងអោយទៅចៅក្រមស៊ើបអង្កេតដើម្បីស៊ើបសួរ
- បង្អង់បណ្តឹងអាជ្ញា រឺរំលត់បណ្តឹងអាជ្ញា
- តំកល់រឿងមិនកាត់ក្តី
- អោយដោះលែងជនល្មើសនៅក្រៅឃុំបណ្តោះអាសន្ន
- យល់ប្រមលើកការចោទប្រកាន់ ។

ចំពោះអយ្យការនៅតុលាការយោធាវិញ អយ្យការមានមុខងារដោះស្រាយតែបទល្មើសយោធាតែប៉ុណ្ណោះ ប្រសិនបើបទល្មើសកើតឡើងរវាងយោធិន និង ជនស៊ីវិលវិញ តុលាការយោធាគ្មានសិទ្ធិដោះស្រាយឡើយ ។

### ខ.មហាអយ្យការអមសាលាឧទ្ធរណ៏

សាលាឧទ្ធរណ៏ ជាសាលាជំរះក្តីជាន់ខ្ពស់ដែលធ្វើការជំនុំជំរះក្តីលើអង្គហេតុ និងអង្គច្បាប់លើបណ្តឹង

ឧទ្ធរណ៍ដែលប្តឹងមកតុលាការខេត្តក្រុង រឺតុលាការយោធាដោយបើកផ្លូវប្តឹងសារទុក្ខ ។ស្ថាប័នអយ្យការអមសាលាឧទ្ធរណ៍មានសមត្ថកិច្ចជំនុំជំរះលាតសន្ធឹងទូទាំងប្រទេស ។

មុខងាររបស់មហាអយ្យការអមសាលាឧទ្ធរណ៍ :

- ធ្វើសេចក្តីសន្និដ្ឋានគ្រប់សំនុំរឿងឧទ្ធរណ៍
- ធ្វើសេចក្តីសន្និដ្ឋាននៅពេលសវនាការ ។

តាមផ្លូវបណ្តឹង : មហាអយ្យការតាំងខ្លួនជាគូក្តីដើមដែលអាចស្នើសុំទៅក្រុមប្រឹក្សាជំនុំជំរះអោយសេចក្តីសំរេចណាមួយដូចជា សំនុំរឿងដែលពាក់ព័ន្ធផលប្រយោជន៍អនីតិជន របៀបរៀបរយសាធារណៈ... ។

តាមផ្លូវយោបល់ : តំណាងមហាអយ្យការតាំងខ្លួនជាគូក្តីរណប គឺគ្រាន់តែផ្តល់យោបល់លើការអនុវត្តន៍ច្បាប់ក្នុងនាមខ្លួនជាតំណាងអោយសង្គម ។ ក្នុងករណីនេះ មហាអយ្យការមិនមែនជាដើមចោទ រឺ ចុងចោទទេ ។

- ប្តឹងសារទុក្ខចំពោះសាលដីកាសាលាឧទ្ធរណ៍ ក្រោយពេលដែលសាលាឧទ្ធរណ៍ចេញសាលដីកា ហើយបើតំណាងអយ្យការមិនសុខចិត្តលើចំនុចណាមួយរបស់សាលដីកាសាលាឧទ្ធរណ៍ ។

- ត្រួតពិនិត្យការងាររបស់ព្រះរាជអាជ្ញាអមតុលាការខេត្តក្រុង ក្នុងករណីដែលមានបទឧក្រិដ្ឋ រឺបទមជ្ឈឹមដែលមានស្ថានទំងន់ទោស ពិសេសព្រះរាជអាជ្ញានៅតុលាការថ្នាក់ក្រោមត្រូវជូនដំណឹងទៅព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ភ្លាម ដើម្បីត្រួតពិនិត្យ ហើយព្រះរាជអាជ្ញានោះត្រូវចាត់ការតាមការបង្គាប់ទាំងឡាយដែលបញ្ជូនមក ។

- ចុះត្រួតពិនិត្យមន្ទីរឃុំឃាំង
- កំណត់ថ្ងៃធ្វើសម្បថរបស់មេធាវីចំពោះមុខសាលាឧទ្ធរណ៍

ចំពោះអ្នកដែលរៀនចប់ផ្នែកវិជ្ជាជីវៈមេធាវី មុនពេលដែលត្រូវបំពេញការងារជាមេធាវីត្រូវឆ្លងកាត់ឆ្លងកាត់ការចុះឈ្មោះដែលមានការអនុញ្ញាតពីគណៈមេធាវីដើម្បីបញ្ជូនមកសាលាឧទ្ធរណ៍ និងព្រះរាជអាជ្ញាធ្វើការពិនិត្យរួចកំនត់ថ្ងៃធ្វើសម្បថ ។

### គ.មហាអយ្យការអមតុលាការកំពូល

មហាអយ្យការអមតុលាការកំពូល ជាស្ថាប័នអយ្យការធំបំផុតដែលដឹកនាំដោយអគ្គព្រះរាជអាជ្ញាធ្វើឡើងតាមការបោះឆ្នោតរបស់រដ្ឋសភា ហើយតែងតាំងដោយព្រះរាជក្រឹត្យ ។ចំណែកឯអគ្គព្រះរាជអាជ្ញារង និងព្រះអាជ្ញាត្រូវធ្វើឡើងតាមរយៈការជ្រើសតាំងតាមសំណើររបស់ក្រសួងយុត្តិធិមដោយព្រះរាជក្រឹត្យ ។

សមត្ថកិច្ចមុខងារមហាអយ្យការតុលាការកំពូល :

- ធ្វើសេចក្តីសន្និដ្ឋានលើសំនុំរឿង ដែលតុលាការកំពូលបញ្ជូនទៅក្រោយពីចៅក្រមធ្វើរបាយការណ៍បញ្ជូនទៅប្រធានតុលាការកំពូល ។

- មហាអយ្យការអាចបង្គាប់អោយក្រឡាបញ្ជីចុះសៀវភៅជំនុំជំរះសំរាប់មុនពេលសវនាការខាងមុខដែលបានឯកភាពពីប្រធានតុលាការកំពូល ។

- ចំពោះរឿងព្រហ្មទណ្ឌ មហាអយ្យការមានតួនាទីតាមដានការឃុំខ្លួន ការដោះលែងជនជាប់ចោទ ។

## ផ្នែកទី២ សមាសភាពនៅក្នុងប្រព័ន្ធតុលាការ

### ១.ចៅក្រម

ចៅក្រមវិជ្ជាជីវៈចែកចេញជា២ប្រភេទ :

- ចៅក្រមអង្គុយ ដែលគេហៅថាចៅក្រមអាសនៈ
- ចៅក្រមឈរ ដែលគេហៅថាចៅក្រមខាងអយ្យការ

### ក.ចៅក្រមអង្គុយ " ចៅក្រមអាសនៈ " Magistrats Du siege

ចៅក្រមនេះមានភារកិច្ចស៊ើបសួររឿង ហើយជំនុំជំរះដោយចេញសាលក្រម Judement រឺចេញសាលដីកានានា Ordonnance ក្នុងរឿងរដ្ឋប្បវេណី ដូចជាតាមលទ្ធភាពសះជាដីកាប្រញាប់ ដីកាលើកបណ្តឹង ដិកាបំបែករឿង ដីកាបំបែកលំនៅបណ្តោះអាសន្ន ។

ការជំនុំជំរះផ្តល់ក្តីយុត្តិធម៌ត្រូវធ្វើឡើងក្នុងប្រជារាស្ត្រខ្មែរ តាមណិតិវិធីច្បាប់ជាធរមាន មានតែចៅក្រមទេដែលមានសិទ្ធិជំរះក្តី ។ចៅក្រមត្រូវបំពេញភារកិច្ចដោយគោរពច្បាប់យ៉ាងម៉ឹងម៉ាត់អោយអស់ពិដួងចិត្ត និងសតិសម្បជញ្ញៈរបស់ខ្លួន ។

ចៅក្រមមិនអាចដកហូតពីមុខងារបានទេ ប៉ុន្តែឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម សំរេចដាក់វិន័យលើចៅក្រមដែលបានប្រព្រឹត្តខុស ។

នៅតុលាការពាណិជ្ជកម្ម និងតុលាការការងារមានចៅក្រមជ្រើសរើសដែលមិនមែនជាចៅក្រមវិជ្ជាជីវះ ។

### ខ.ចៅក្រមឈរ រឺចៅក្រមខាងអយ្យការ Magistrats debout ou Ministrere public

ចៅក្រមនេះជាព្រះរាជអាជ្ញា ព្រះរាជអាជ្ញា ព្រះរាជអាជ្ញារង អគ្គព្រះរាជអាជ្ញា និងអគ្គព្រះរាជអាជ្ញារងដែលតំណាងអោយនីតិប្រតិបត្តិនៅចំពោះមុខសាលាជំរះក្តី និងជាអ្នកការពារច្បាប់រដ្ឋ ។ព្រះរាជអាជ្ញា

និងអគ្គព្រះរាជអាជ្ញាដឹកនាំអយ្យការអមតុលាការ ។ព្រះរាជអាជ្ញាត្រួតពិនិត្យការគោរពច្បាប់ ធ្វើការចោទប្រកាន់ទោសទៅលើជនល្មើសពីបទព្រហ្មទណ្ឌ ឃ្លាំមើលការប្រព្រឹត្តទៅនៃនីតិវិធី ។អយ្យការទទួលបន្ទុកការពារផលប្រយោជន៏ទូទៅរបស់សង្គម ។ព្រះរាជអាជ្ញាជាមេធាវីរបស់សង្គម ។

បុព្វហេតុដែលគេហៅអយ្យការថាជាចៅក្រមឈរ ពីព្រោះពេលបំពេញការងារនៅក្នុងសវនាការចោទប្រកាន់ទៅតុលាការដោយក្រោកឈរជានិច្ច ។

ព្រះរាជអាជ្ញាអាចទទួលបញ្ជាធ្វើការចោទប្រកាន់ពីរដ្ឋមន្ត្រីក្រសួងយុត្តិធម ។

មាត្រា១៣១ នៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជាបានចែងថា " មានតែអង្គការអយ្យការទេដែលមានសិទ្ធិធ្វើបណ្ដឹងអាជ្ញា" ។

**ក្នុងរឿងក្ដីព្រហ្មទណ្ឌ**

អង្គការអយ្យការជាម្ចាស់បណ្ដឹងអាជ្ញា និងធ្វើសេចក្ដីសន្និដ្ឋានទោសដោយតាំងខ្លួនជាគូក្ដីដើមជានិច្ច

**ក្នុងរឿងរដ្ឋប្បវេណី**

អង្គការអយ្យការជាគូក្ដីរណប គឺគ្រាន់តែជាអ្នកអោយយោបល់ យល់ឃើញថាជាការគួរ ។ ប៉ុន្តែក្នុងរឿងខ្លះដែលទាក់ទងរបៀបរៀបរយសាធារណៈ រឺ ផលប្រយោជន៏អនីតិជន រឺ អសមត្ថជន តំណាងអយ្យការត្រូវតាំងខ្លួនជាគូក្ដីដើម ។

**២.ក្រឡាបញ្ជី Greeffier**

សាលាជំរះក្ដីអាចដំណើរការបានដោយសារវត្តមានក្រឡាបញ្ជី ។

**ក្រឡាបញ្ជីមានភារកិច្ចសំខាន់១២យ៉ាង :**

ក.ជាជំនួយការដល់ចៅក្រម មុនពេលសវនាការ

ពេលសវនាការធ្វើអោយមានយថាភូតភាពសវនាការ ។ ក្រឡាបញ្ជីមានលក្ខណ:ជាមន្ត្រីសាធារណៈ ហើយធានាអោយមាននិយ័តភាពនៃកិច្ចការរបស់ចៅក្រម ហើយនឹងការដេញដោលនៅពេលសវនាការរបស់ចៅក្រម ក្រឡាបញ្ជីកាន់បញ្ជីសំនុំរឿងផ្សេងៗ ។

ខ.បំពេញគ្រប់កិច្ចការរដ្ឋបាល មុនដាក់ជូនរឿងមួយដាក់ចៅក្រមដើម្បីពិនិត្យមុនពេលសវនាការក្រោយពេលសវនាការ ក្រឡាបញ្ជីទទួលបន្ទុកសរសេរសាលក្រមអោយដំណឹងពីសាលក្រម ។

ក្រឡាបញ្ជីចុះហត្ថលេខាលើសាលក្រម និងរក្សាទុកឯកសារ ។ក្រឡាបញ្ជីជាមន្ត្រីរបស់រដ្ឋទទួលបៀវត្សពីរដ្ឋ ។គ្រប់សាលាជំរះក្ដីទាំងអស់មានក្រឡាបញ្ជី ១រូប ដែលដឹកនាំក្រឡាបញ្ជីនាយក ១រូប ។ក្រឡាបញ្ជី

នាយកត្រូវស្ថិតនៅក្រោមការត្រួតពិនិត្យរបស់ប្រធានតុលាការ និងព្រះរាជអាជ្ញា ។

ក្រឡាបញ្ជីនាយកមានក្រឡាបញ្ជីជំនួយការ និងបុគ្គលិកមួយចំនួន ។

មុនពេលសវនាការ ក្រឡាបញ្ជីត្រូវសរសេរដីកាកោះហៅដើមបណ្តឹងរដ្ឋប្បវេណី សាក្សី មេធាវី លិខិតបង្គាប់អោយនាំជនជាប់ចោទអោយមកជំនុំជំរះដើម្បីចូលសវនាការ ។ នៅពេលសវនាការ ក្រឡាបញ្ជីត្រូវហៅសាក្សីអោយទៅស្បថជាមុនសិន ទើបបង្ហាញកន្លែងអង្គុយ ដើម្បីរងចាំស្តាប់ការហៅអោយចូលខ្លួនរបស់ចៅក្រមជំនុំជំរះ ។ជាមួយគ្នានោះដែរ ក្រឡាបញ្ជីក៏ត្រូវអានសណ្តាប់ធ្នាប់ បទបញ្ជាផ្ទៃក្នុងបន្ទប់សវនាការ ។ក្រឡាបញ្ជីត្រូវចុះបណ្តឹងឧទ្ធរណ៍ និងបណ្តឹងទាស់នៅក្នុងសៀវភៅ ហើយចេញបង្កាន់ដៃអោយគេផង និងរៀបចំសំនុំរឿងបញ្ជូនទៅសាលាឧទ្ធរណ៍ ។ចំពោះបណ្តឹងទាស់ ក្រឡាបញ្ជីត្រូវរៀបចំដាក់ជំនុំជំរះម្តងទៀត ។

**- សមាសភាពដែលមិនចាត់ចូលស្ថាប័នតុលាការ**

**១.មេធាវី** ប្រកបរបរវិជ្ជាជីវៈឯករាជ្យ និង ដោយសេរីដើម្បីចូលរួមក្នុងវិស័យយុត្តិធម ហើយមិនស្ថិតនៅក្រោមអំនាចណាមួយឡើយ ។ មេធាវីអាចតំណាងគូក្តីតាមការយល់ព្រម រឺ ជួយការពារកូនក្តីនៅគ្រប់សាលាជំរះក្តី និងគ្រប់ដំណាក់នៃនីតិវិធី ជាពិសេសក្នុងរឿងរដ្ឋប្បវេណី ពាណិជ្ជកម្ម ការងារជាដើម ។ប៉ុន្តែក្នុងរឿងព្រហ្មទណ្ឌ មេធាវីអាចជំទាស់បទចោទប្រកាន់លើកូនក្តីរបស់ខ្លួន ហើយអាចជំទាស់ជិតចិត្តចៅក្រមបាន អាចធានាកូនក្តីត្រូវចោទពីបទឧក្រិដ្ឋ ប៉ុន្តែអាចជួយកូនក្តីបានគ្រប់ពេលវេលា និងគ្រប់សាលាជំរះក្តី អាចស្រាវជ្រាវការពិតធ្វើអោយកូនក្តីរួចទោស រឺសំរាលទោសតាមនីតិវិធី ហើយនិយាយការពារផលប្រយោជន៏អោយកូនក្តីជានិច្ច ។

តាមច្បាប់ស្តីពីលក្ខន្តិកៈមេធាវី ថ្ងៃទី១៥ ខែមិថុនា ឆ្នាំ១៩៩៥ មេធាវីអាចផ្តល់យោបល់ និងតាក់តែងលិខិតស្នាមគតិយុត្តផ្សេងៗក្នុងវិស័យយុត្តិធម ហើយអាចបំពេញភារកិច្ចជាអ្នកផ្សះផ្សារ សម្រុះសម្រួលតាមការចាត់តាំងរបស់គូក្តី រឺចៅក្រមបំពេញមុខងារ ។

មេធាវីសុទ្ធតែប្រកបវិជ្ជាជីវៈរបស់ខ្លួនដោយសេចក្តីថ្លៃថ្នូរ ដោយសតិសម្បជញ្ញៈ ដោយទៀងត្រង់ ដោយមនុស្សធម ដោយស្មារតីឯករាជ្យ និងដោយគោរពច្បាប់ ។ ពិសេស គឺច្បាប់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាកម្ពុជាហើយម្យ៉ាងទៀតកិច្ចការមេធាវីធ្វើឡើងសំរាប់អនីតិជន គ្មានជនណាអាចបង្ខំអោយបំពារបំពានលើការសំងាត់បានឡើយ ទោះបីនៅមុខតុលាការក៏ដោយ ។

**- មេធាវីសព្វថ្ងៃមេធាវីមាន ២ប្រភេទគឺ :**

**ក. មេធាវីឯកជន**

ជាមេធាវីដែលបើកការិយាល័យប្រកបវិជ្ជាជីវៈដោយខ្លួនឯង ពោលគឺរកប្រាក់កំរៃដោយខ្លួនឯងពុំមានប្រាក់បំណាច់ទេ ប្រាក់ដែលបានបំពេញភារកិច្ច គឺអាស្រ័យលើការព្រមព្រៀងរបស់មេធាវី និង អតិថិជនរបស់ខ្លួន ។

**ខ.មេធាវីស្ម័គ្រចិត្តការពារជនក្រីក្រ**

ជាមេធាវីដែលទទួលប្រាក់កំរៃការងារពីបេឡាពិសេសនៃមូលនិធិគណៈមេធាវី ប្រាក់បេឡាពិសេសសំរាប់ផ្តល់អោយមេធាវីស្ម័គ្រចិត្តការពារជនក្រីក្រ ។ ប្រាក់ទាំងនោះបានមកពីអំណោយ រឺ ជំនួយឯកជនអង្គការអន្តរជាតិ រឺរដ្ឋាភិបាលនៃប្រទេសផ្សេងៗផ្តល់អោយមេធាវីនេះមិនយកកំរៃពីកូនក្តី រឺ ជនដែលខ្លួនការពារក្តីអោយទេ ។សព្វថ្ងៃ ប្រទេសកម្ពុជាមានអង្គការស្ម័គ្រចិត្តរបស់មេធាវី អង្គការការពារគំរោងអ្នកការពារក្តីកម្ពុជា និង អង្គការជំនួយផ្នែកច្បាប់នៃកម្ពុជាដែលសហការជាមួយមេធាវីកម្ពុជា ពោលគឺមេធាវីស្ម័គ្រចិត្តបំពេញភារកិច្ចដូចគ្នានឹងមេធាវីឯកជនដែរ ។

**២.អាជ្ញាសាលា**

ជាបុគ្គលិកដែលក្រសួងយុត្តិធម៌អនុញ្ញាតអោយមកធ្វើការជាប្រចាំនៅសាលាក្តី និង មានភារកិច្ចអនុវត្ត រឺចាត់ការតាមដីការបស់តុលាការ ដូចជាការយកដីកាអនុវត្តសាលក្រម សាលដីកា ។ល ។ហើយរៀបរងនីតិខ្លះៗអោយដំណឹងដល់ភាគី ។ជាពិសេស អាជ្ញាសាលាទទួលបន្ទុកអនុវត្តសេចក្តីសំរេចរបស់តុលាការ ដូចជាការរឹបអូស បណ្តេញចេញអ្នកជួលផ្ទះ និង ធ្វើការពិនិត្យកត់ត្រាតាមការស្នើសុំរបស់ឯកជន រឺរបស់ចៅក្រម ។

**៣.អ្នកជំនាញ**

ជាអ្នកបច្ចេកទេស ដូចជាគ្រូពេទ្យ ស្ថាបត្យករ គីមីសាស្ត្រ អាវុធ ជាតិផ្ទុះ...ដែលចាត់តាំងដោយសាលាជំរះក្តីដើម្បីបំពេញបេសកម្មផ្តល់ពិតមាន និងផ្ទៀងផ្ទាត់ផ្នែកបច្ចេកទេស និង ការស្រាវជ្រាវយ៉ាងពេញលេញដែលមិនចាត់ចូលជាសមាជិកចៅក្រម ដើម្បីអោយផ្តល់នូវកោសល្យដែលខ្លួនបានស្រាវជ្រាវ នៅពេលដែលចៅក្រមបានសុំអោយអ្នកជំនាញបំភ្លឺតុលាការអំពីចំនុចសំខាន់ខ្លះៗនៃរឿងក្តីបដែលទាមទារមតិរបស់អ្នកជំនាញសំរាប់ធ្វើជាមូលដ្ឋាននៃការវាយតំលៃកាត់សេចក្តីរបស់ចៅក្រម ។

**៤.សារការី**

ជាមន្ត្រីសាធារណៈជំនួយតុលាការ មានមុខងារខាងទទួលលិខិតទាំងឡាយ ដែលភាគីត្រូវការអោយមានការបញ្ជាក់អំពីលក្ខណៈពិតប្រាកដ ធានារ៉ាប់រងអំពីកាលបរិច្ឆេទតំកល់រក្សាទុក និង ចេញសេចក្តីចំលង

ដែលមានរូបមន្តអនុវត្តនៃលិខិតនោះ។

**៩.មន្ត្រីនគរបាលយុត្តិធម**

ការងារមន្ត្រីនគរបាលយុត្តិធមត្រូវអនុវត្តតាមប្រកាសរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម ។ បច្ចេកទេសមន្ត្រីនគរបាលយុត្តិធមស្ថិតនៅក្រោមរដ្ឋមន្ត្រីក្រសួងយុត្តិធម និងក្រោមអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍។ បុព្វហេតុដែលនាំអោយការងារយុត្តិធមនៅក្រោមរដ្ឋមន្ត្រីក្រសួងយុត្តិធម ពីព្រោះស្ថិតនៅក្រោមការដឹកនាំនីតិវិធីបច្ចេកទេសគតិយុត្ត។

**មន្ត្រីនគរបាលយុត្តិធមមានសមត្ថកិច្ចចាត់ចែងប្រតិបត្តិការងារដូចតទៅ :**

- មន្ត្រីនគរបាលយុត្តិធមនៅកន្លែងបទល្មើសកើតឡើង
- មន្ត្រីនគរបាលយុត្តិធមខាងលំនៅដ្ឋានរបស់ជនល្មើស
- មន្ត្រីនគរបាលយុត្តិធមកន្លែងដែលជនល្មើសត្រូវបានរកឃើញ
- ទទួលពាក្យបណ្តឹងទាមទារ បណ្តឹងបរិហារព្រមទាំងរបាយការណ៍នគរបាលយុត្តិធមទាក់ទងនឹងបទល្មើសឧក្រិដ្ឋ និងមជ្ឈឹម
- ចាត់ចែងប្រមូលការងារនានា
- អាចស្នើសុំជំនួយពីកំលាំងសាធារណៈដើម្បីធ្វើកំណត់ហេតុ
- អាចទទួលលិខិតបង្គាប់ការអោយសួរជំនួស
- អាចសំរេចការឃាត់ខ្លួនបានក្នុងរយៈពេល ៤៨ ម៉ោងយ៉ាងយូរបំផុត
- ក្នុងករណីបទឧក្រិដ្ឋនិងបទមជ្ឈឹមជាក់ស្តែងអាចសួរយកចំលើយសាក្សី ធ្វើការឆែកឆេរ និងរឹបអូសវត្ថុតាង អាចចាត់តាំងអ្នកជំនាញសំរេចការឃាត់ខ្លួនបានក្នុងរយៈពេល ៤៨ ម៉ោងយ៉ាង យូរបំផុត ប្រសិនបើមានវត្ថុតាង រឺ មានការសង្ស័យដែលមានមូលដ្ឋានច្បាស់លាស់សំរេចធ្វើការចោទប្រកាន់បាន។

យោងលើច្បាប់ស្តីពីវិសោធនកម្មមាត្រា ៣៦ ៣៨ ៩០ និងមាត្រា៩១នៃច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ មាត្រា៣៦ បានចែងថា :

ចាត់ទុកជាមន្ត្រីនគរបាលយុត្តិធមរួមមាន :( មានចែងក្នុងមាត្រា៦០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ )

១.ព្រះរាជអាជ្ញា និងចៅក្រមស៊ើបអង្កេត " ក្នុងភារកិច្ចតែប៉ុណ្ណោះ "

២.អភិបាល អភិបាលរងខេត្តក្រុង អភិបាល អភិបាលរងស្រុកខណ្ឌ និងមេឃុំ ចៅសង្កាត់

៣.ប្រធាន អនុប្រធាននាយកដ្ឋាន ប្រធាន អនុប្រធានការិយាល័យ និងប្រធាន អនុប្រធានផ្នែក

- នាយកដ្ឋាននគរបាលព្រហ្មទណ្ឌ
- នាយកដ្ឋាននគរបាលសេដ្ឋកិច្ច
- នាយកដ្ឋាននគរបាលបច្ចេកទេសវិទ្យាសាស្ត្រ
- នាយកដ្ឋានប្រឆាំងភេរវកម្ម
- នាយកដ្ឋាននគរបាលព្រំដែន " ចំពោះបទល្មើសឆ្លងដែន "
- នាយកដ្ឋានជនបរទេស
- មន្ទីរប្រឆាំងគ្រឿងញៀន

៤.ស្នងការនគរបាលខេត្តក្រុង

៥.ប្រធាន អនុប្រធានការិយាល័យ និងប្រធាន អនុប្រធានផ្នែកដែលទទួលបន្ទុកការងារ ព្រហ្មទណ្ឌចំណុះស្នងការនគរបាលខេត្តក្រុងដូចជា :

- ការិយាល័យនគរបាលព្រហ្មទណ្ឌកំរិតធ្ងន់
- ការិយាល័យនគរបាលព្រហ្មទណ្ឌកំរិតស្រាល
- ការិយាល័យនគរបាលសេដ្ឋកិច្ច
- ការិយាល័យបច្ចេកទេសវិទ្យាសាស្ត្រព្រហ្មទណ្ឌ
- ការិយាល័យប្រឆាំងគ្រឿងញៀន
- ការិយាល័យប្រឆាំងភេរវកម្ម
- ការិយាល័យជនបរទេស

៦.អធិការ អធិការរង និងប្រធាន អនុប្រធានផ្នែកព្រហ្មទណ្ឌនៃអធិការដ្ឋាន នគរបាលស្រុកខណ្ឌ

៧.ប្រធាន ងនុប្រធានការិយាល័យនគរបាលចរាចរណ៍ និងប្រធាន អនុប្រធានផ្នែកនគរបាលចរាចរណ៍ " ចំពោះបទល្មើសចរាចរ "

៨.ប្រធាន អនុប្រធានប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំសង្កាត់ចំពោះបទល្មើសព្រហ្មទណ្ឌ

៩.មេបញ្ជាការ មេបញ្ជាការរង ព្រមទាំងមន្ត្រី ចាប់ពីប្រធានផ្នែកឡើងទៅនៃកងរាជអាវុធហត្ថដែល ទទួលការងារព្រហ្មទណ្ឌ ។ " ចំពោះបទល្មើសដែលទាក់ទងនឹងកិច្ចការយោធា "

១០.មន្ត្រីនៃក្រសួង រឺស្ថាប័នណាដែលច្បាប់បានប្រគល់អំនាច និងសំរបសំរួលរបស់ព្រះរាជអាជ្ញាលើនី

តិវិធី និងវិធានស៊ើបអង្កេតដើម្បីធានាការចោទប្រកាន់អោយមានប្រសិទ្ធិភាព ក្រោមការត្រួតពិនិត្យរបស់អគ្គព្រះរាជអាជ្ញាសាលាឧទ្ធរណ៏ ។

**ក.តួនាទី និងមុខងារនគរបាលយុត្តិធម**

នគរបាលយុត្តិធម គឺជាក្រុមមនុស្សដែលថែរក្សាប្រជាជននៅតំបន់ ដែលខ្លួនបានគ្រប់គ្រង ដែលមាននាទីគ្រប់គ្រងមុខងារដូចខាងក្រោម :

♦ **តួនាទី**

- ការពារអាយុជីវិតសិទ្ធិសេរីភាព សេចក្តីថ្លៃថ្នូររបស់ជនគ្រប់រូប និងទ្រព្យសម្បត្តិស្របច្បាប់របស់ឯកជន និងទ្រព្យសម្បត្តិសាធារណៈ
- រក្សាសន្តិសុខ សុវត្ថិភាព និងសណ្តាបលធ្លាប់សាធារណៈ
- បង្ការ និងតាមដានរកអោយឃើញបទល្មើសគ្រប់ប្រភេទ
- ជួយដល់សាធារណៈជនក្នុងកាលៈទេសៈមានគ្រោះអាសន្ន ។ដូច្នេះគ្រប់ពេលវេលាត្រូវតាំងចិត្តមោះមុតក្នុងការបំពេញតួនាទីរបស់ខ្លួនអោយបានល្អបំផុត

♦ **មុខងារ**

នគរបាលមានមុខងារទូទៅក្នុងសង្គម គឺរក្សានូវរបៀបរៀបរយ និងសណ្តាប់ធ្នាប់សាធារណៈ ការពារប្រជាពលរដ្ឋ និងបង្ការបទល្មើស ។ ស្ថាប័នប៉ូលីសជំនាញជាច្រើនបានបង្កើត ដើម្បីបំពេញតួនា ទីផ្សេងៗគ្នានៅក្នុងសង្គម ។

**២.អំនាច និងភារកិច្ចនគរបាលយុត្តិធម**

ក្នុងនាមខ្លួនជាអ្នកស៊ើបអង្កេតរកបទល្មើសគ្រប់ប្រភេទ និងប្រមូលភស្តុតាងនោះ មន្ត្រីនគរបាលយុត្តធិមត្រូវបានច្បាប់ប្រគល់អោយនូវសិទ្ធិអំនាចមួយចំនួន ដើម្បីធ្វើប្រតិបត្តិការរបស់ខ្លួនដូចតទៅ :

- ទទួលពាក្យបណ្តឹងទាមទារបណ្តឹងបរិហារ ព្រមទាំងរបាយការណ៏នគរបាលយុត្តិធិមដែលទាក់ទងបទល្មើសព្រហ្មទណ្ឌ
- ធ្វើការស៊ើបអង្កេតដោយផ្ទាល់ និងចាត់ចែងប្រមូលភស្តុតាង
- ស្នើសុំកំលាំងជំនួយពីកំលាំងសាធារណៈ
- យកចំលើយពីជនសង្ស័យ និងសាក្សី
- ទទួលលិខិតបង្គាប់អោយសួរជំនួស

- ក្នុងករណីបទល្មើសជាក់ស្តែងអាចដូចជា :
    - ចាប់ខ្លួនជនសង្ស័យ
    - ឆែកឆេរលំនៅដ្ឋានជនសង្ស័យ និងកន្លែងផ្សេងៗទៀត ដើម្បីស្រាវជ្រាវរកភស្តុតាង
    - រឹបអូសវត្ថុទាំងឡាយ ដែលចាត់ទុកថាជាភស្តុតាង
    - សួរចំលើយសាក្សី ដែលពាក់ព័ន្ធនឹងបទល្មើស
    - ឃុំខ្លួនជនសង្ស័យបាន ៤៨ ម៉ោង
- កត់ត្រានូវការរកឃើញរបស់ខ្លួន និងភស្តុតាងក្នុងរបាយការណ៏
- ក្នុងរយៈពេលមួយយ៉ាងខ្លី ត្រូវបញ្ជូនរបាយការណ៏ដោយភ្ជាប់មកជាមួយនូវវត្ថុតាងទៅអោយព្រះរាជអាជ្ញា រឺចៅក្រមក្នុងរយៈពេល ៤៨ ម៉ោង
- ក្នុងករណីណាក៏ដោយ មន្ត្រីនគរបាលយុត្តិធម៌គ្មានសិទ្ធិតំកល់ទុកឥតចាត់ការនូវរឿងអាជ្ញាដែលខ្លួនបានទទួល ទោះបីមានភាពសំរុះសំរួលគ្នាហើយក៏ដោយ គឺត្រូវធ្វើកំនត់ហេតុជុនទៅព្រះរាជអាជ្ញាមានសមត្ថកិច្ចជាដរាប
- នាំជនសង្ស័យទៅចំពោះមុខព្រះរាជអាជ្ញា រឺចៅក្រមក្នុងរយៈពេល ៤៨ ម៉ោង

### ៣.អំពីតំលៃកំនត់ហេតុរបស់មន្ត្រីនគរបាលយុត្តិធម

កំនត់ហេតុដែលធ្វើឡើងដោយមន្ត្រីនគរបាលយុត្តិធម៌ខ្លួនឯង ហើយធ្វើឡើងគោរពតាមទំរង់បែបបទដែលកំនត់ក្នុងមាត្រា ៤០នៃនីតិវិធីព្រហ្មទណ្ឌឆ្នាំ ១៩៩៣ ត្រូវបានចាត់ចូលជាភស្តុតាងដែលតុលាការ និងចៅក្រមត្រូវតែជឿ បើគ្មានភស្តុតាងផ្ទុយមកបញ្ជាក់ទេនោះ។ ( មាត្រា៤២នៃច្បាប់និតិព្រហ្មទណ្ឌឆ្នាំ ១៩៩៣ )

តាមសាលដីកាមួយរបស់តុលាការកំពូល នៅក្នុងអំឡុងឆ្នាំ ២០០០-២០០៣ បានបដិសេធសាលដីកាមួយរបស់សាលាឧទ្ធរណ៏ដែលបានសំរេចជនជាប់ចោទរួចខ្លួនពីបទចោទប្រកាន់ដោសាលាឧទ្ធរណ៏លើសំអាងថាគ្មានភស្តុតាងគ្រប់គ្រាន់ ប៉ុន្តែតុលាការកំពូលយល់ឃើញថាមានភស្តុតាងគ្រប់គ្រាន់ គឺកំនត់ហេតុរបស់មន្ត្រីនគរបាលយុត្តិធម ដែលពុំទាន់មានភស្តុតាងផ្ទុយមកបញ្ជាក់ទេ។

ប៉ុន្តែកំណត់ធ្វើដោយភ្នាក់ងារប៉ូលីស មិនមែននគរបាលយុត្តិធម ដូចបានកំណត់ក្នុងមាត្រា ៣៦ នៃច្បាប់នីតិវិធីព្រហ្មទណ្ឌ ឆ្នាំ១៩៩៣ គឺគ្រាន់តែទុកជាពិតមានតែប៉ុណ្ណោះ ដែលមិនបង្ខំអោយចៅក្រម រឺ សាលាជំរះក្តីជឿតាមនោះទេ។